# នរោត្តម សីហនុ
# នៃកម្ពុជា

ប៉េកាំង ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០០៥

ខ្ញុំមានកិត្តិយសសូមជូនជ្រាបនូវការពិតអំពីបញ្ហាកម្ពុជាក្រោមម្តងទៀត និងអំពីកោះត្រល់ ព្រមទាំងបន្ទាត់ប្រេវិយេ (ligne Brévié), Brévié ជាឈ្មោះលោកអគ្គទេសាភិបាលបារាំងដែលត្រួតត្រាឥណ្ឌូចិនបារាំងសែស ( ខ្មែរ វៀតណាម និងលាវ ) ។

១- **អំពីកម្ពុជាក្រោម** : ខ្ញុំបានជំរាបជាច្រើនលើកហើយនូវការពិតជាប្រវត្តិសាស្ត្រអំពីបញ្ហាកម្ពុ-ជាក្រោម ។ តែដោយនៅពេលនេះមានមារសត្រូវ នរោត្តម សីហនុ នៅក្រៅប្រទេស និងក្នុងប្រទេស បានចោទប្រកាន់ខ្ញុំថា ក្បត់ជាតិ លក់ទិកដីឲ្យបារាំង និងវៀតណាម ខ្ញុំសូមបន្ថែមនូវសេចក្តីដូចតទៅនេះ:

កើតមកជាខ្មែរ គ្មានអ្នកណាម្នាក់ដែលមិនស្រឡាញ់ជាតិ ស្រឡាញ់កម្ពុជាក្រោម និងកោះត្រល់នោះទេ ។ ខ្ញុំមិនដែលបានចោទប្រកាន់អ្នកណាម្នាក់ ថាមិនចេះស្រឡាញ់ជាតិនោះទេ ។ ខ្ញុំសូមលើកមកជំរាបតែអំពីគ្រួសារខ្ញុំ :

-នៅសតវត្សរ៍ទី២០គ្រួសារខ្ញុំ ទទួលរងទុក្ខវេទនាដោយសារកម្ពុជាក្រោម ។ ខ្មែរកម្ពុជាក្រោមជាច្រើនបានសុំឲ្យមាខ្ញុំតស៊ូទាមទារយកកម្ពុជាក្រោមមកបញ្ចូលជាមួយកម្ពុជាលើវិញ ។ លោកមានត្រកូលនរោត្តម ហើយព្រះអង្គសុគត់ ដោយធ្វើអត្តឃាតចងព្រះសុរង ។ មូលហេតុនៃការធ្វើអត្តឃាត គឺបណ្តាលមកពីព្រះអង្គមានការឈឺចាប់ក្នុងហឫទ័យ និងការអៀនខ្មាស់ដោយសារការខិតខំទាមទារកម្ពុជាក្រោមពីបារាំងសែសមិនទទួលបានជោគជ័យ ។ ព្រះអង្គសុខចិត្តធ្វើពលិកម្មរហូតដល់ជីវិត ។

-ខ្មែរកម្ពុជាក្រោមឡើងចុះតំណាក់ជីតាខ្ញុំផ្ទាល់ ព្រះនាម ព្រះនរោត្តម សុធារស ហើយសុំឲ្យព្រះនរោត្តម សុធារស សន្យាថានៅពេលព្រះអង្គឡើងគ្រងរាជសម្បត្តិ ព្រះអង្គត្រូវទាមទារកម្ពុជាក្រោមពីបារាំងសែសមកឲ្យកម្ពុជាលើវិញ កុំឲ្យបានទៅវៀតណាម ។ ព្រះនរោត្តម សុធារស បានសន្យាជាមួយខ្មែរកម្ពុជាក្រោមទាំងនោះថា បើបារាំងថ្វាយរាជសម្បត្តិមកព្រះអង្គ ក្រោយពីព្រះករុណាព្រះបាទស៊ីសុវត្ថិចូលទីវង្គត់ ព្រះអង្គនិងទាមទារពីបារាំងឲ្យទាល់តែបានកម្ពុជាក្រោមមកភ្ជាប់ជាមួយនិងកម្ពុជាលើវិញដូចបុរាណសម័យ ។ នៅពេលនោះបារាំងសែសគិតគូរថ្វាយរាជបល្ល័ង្កមកសាខាច្បង នរោត្តមវិញ បានសេចក្តីថាក្រោយព្រះបាទស៊ីសុវត្ថិ និងថ្វាយព្រះនរោត្តមម្នាក់ឡើងគ្រងរាជ្យសម្បត្តិ ។ បារាំងបានប៉ានព្រះឆាយាល័ក្ខ ព្រះនរោត្តម សុធារស ដើម្បីដាក់តាំងនៅពេលព្រះអង្គឡើងគ្រងរាជ្យ ។ ដោយទទួលពត៌មានពីភ្នាក់ងារសំងាត់ថានៅ

ពេលព្រះអង្គឡើងគ្រងរាជ្យ ព្រះអង្គនិងទាមទារកម្ពុជាក្រោមពីបារាំងភ្លាម បារាំងសែសក៏សំរេចឈប់ថ្វាយព្រះនរោត្តម សុធារស សោយរាជ្យ ហើយយកព្រះឆាយាល័ក្ខព្រះអង្គដែលថតរួចហើយ ទៅទម្លាក់នៅក្នុងទន្លេបួនមុខ ។ ព្រះនរោត្តម សុធារស ក៏អស់រាជ្យសម្បត្តិដោយសេចក្ដីស្នេហាជាតិរបស់ព្រះអង្គ ។

ទាំងអស់ខាងលើនេះបង្ហាញឲ្យឃើញថាគ្រួសារខ្ញុំតែងតែធ្វើពលិកម្មគ្រប់បែបយ៉ាង ដើម្បីជាតិមាតុភូមិ ។ ចំណែកខ្ញុំវិញ ប្រវត្តិសាស្ត្របានកត់ត្រាទុកអស់ហើយអំពីពលិកម្ម និងការតស៊ូរំដោះជាតិជាច្រើនលើក ច្រើនគ្រា ដើម្បីឯករាជ្យពីអាណានិគមនិយមបារាំង ពីចក្រពត្តិនិយមអាមេរិកាំង ហើយនិងពីអាណានិគមនិយមវៀតណាម ។

អំពីកម្ពុជាក្រោមនេះ ខ្ញុំក៏មានមហិច្ឆិតាចង់បាន ដើម្បីឲ្យកម្ពុជាលូតលាស់ទូលំទូលាយ មិនមែនក្រៀមក្រំ ហើយតូចនោះទេ ។ ខ្ញុំមិនដែលបានសរសេរ ឬនិយាយថា ខ្ញុំសុខចិត្តសុខកាយប្រគល់កម្ពុជាក្រោមទៅវៀតណាមនោះទេ ។ ខ្ញុំធ្លាប់ប្រកាសប្រាប់បារាំងថា ខ្ញុំមិនសុខចិត្តនិងបារាំង ដែលផ្ទេរកម្ពុជាក្រោមទៅព្រះចៅ បាវ ដាយ ។ បើត្រូវផ្ទេរ គឺត្រូវផ្ទេរកម្ពុជាក្រោមយ៉ាងតិចពាក់កណ្ដាលមកកម្ពុជាលើដែរ ពីព្រោះនៅក្នុងឆ្នាំ១៨៦០ បារាំងបានចូលមកកូសាំងស៊ីន ហើយឃើញខ្មែរ និងវៀតណាមកំពុងតែប្រយុទ្ធគ្នា ។ ខ្មែរច្បាំងការពារកម្ពុជាក្រោម ហើយវៀតណាមចង់លេបត្របាក់កម្ពុជាក្រោម ។ កងទ័ពបារាំងខ្លាំង ហើយវាយបង្ក្រាបកងទ័ពខ្មែរ និកងទ័ពវៀតណាម ។ បារាំងលេបត្របាក់កម្ពុជាក្រោមធ្វើជាខេត្តរបស់បារាំង ។ ក្រោយមកទៀតបារាំងចង់ជួយ បាវ ដាយ ឲ្យមានកេរ្ដិ៍ឈ្មោះចំពោះប្រជាជាតិវៀតណាម ដើម្បីកុំឲ្យហូជីមិញ ច្បាំងនិងបារាំងឈ្នះ បារាំងក៏ផ្ទេរកម្ពុជាក្រោមថ្វាយព្រះចៅ បាវ ដាយ ទៅ ។ ខ្ញុំបានបញ្ជូនសម្ដេច ប៉ែន នុត-សម្ដេច សឺន សាន-ឯកឧត្តម សម សារី ទៅតវ៉ាជាបន្តបន្ទាប់ជាមួយបារាំងថាខ្ញុំពុំសុខចិត្តសុខកាយ ចំពោះការផ្ទេរកម្ពុជាក្រោឲ្យទៅវៀតណាមទេ ។

ខ្ញុំបានបង្គាប់ទៅឥស្សរជនដែលខ្ញុំជ្រើសរើសឲ្យធ្វើជាសមាជិក សមាជិកាក្នុងសភាសហភាពបារាំងនៅមុនឆ្នាំ១៩៥៣ (ក្នុងនោះមានម្ដាយមីងខ្ញុំម្នាក់មួយឈ្មោះព្រះអង្គម្ចាស់ នរោត្តម ពីង ពាង) ឲ្យតវ៉ាកុំឲ្យសុខចិត្តនិងបារាំងផ្ទេរកម្ពុជាក្រោមទៅ បាវ ដាយ ។ នៅពេលដែលបានឯករាជ្យបរិបូណ៌ហើយ ខ្ញុំបានដកកម្ពុជាចេញពីសហភាពបារាំងសែស ។

២- **អំពីបន្ទាត់ប្រេវិយេ :** ខ្ញុំមិនដែលបាននិយាយថា ខ្ញុំយល់ព្រម យល់ស្របជាមួយបារាំងសែសអំពីបន្ទាត់ប្រេវិយេនេះទេ ។ នៅឆ្នាំ១៩៥៥ ឯកឧត្តមនាយករដ្ឋមន្ត្រី ជូ អេនឡាយ-ឯកឧត្តមសេនាប្រមុខ ចេន យី និងគណៈប្រតិភូនៃសាធារណរដ្ឋ ប្រជាមានិតចិន បានជិះកប៉ាល់ចំបាំងតូចមួយជាមួយខ្ញុំទៅជិតកោះត្រល់ ហើយខ្ញុំបានចង្អុលប្រាប់គណៈប្រតិភូចិន និងជំរាបថាកោះត្រល់ជារបស់ខ្មែរដែលបារាំង

ប្រើអំណាចរំលោភយកដោយខុសច្បាប់ពីខ្មែរ រួចផ្ទេរទៅឲ្យ បាវ ដាយ ។ ខ្ញុំបានឮយ៉ាងច្បាស់ពីឯកឧត្តម ជូ អេនឡាយ និងឯកឧត្តមសេនាប្រមុខ ចេន យី ដែលជាវារបុរសដ៏ចំណាស់ជាមួយឯកឧត្តម ម៉ៅ សេ ទុង ក្នុងការតស៊ូដើម្បីរំដោះជាតិនៃមហាប្រទេសចិន បានមានប្រសាសន៍ថា : ច្បាស់ណាស់កោះត្រល់ជារបស់ខ្មែរត្បិតជាប់និងទឹកដីខ្មែរ មិនជាប់ជាមួយទិកដីវៀតណាមទេ ។ ហេតុអ្វីបានជាបារាំងធ្វើយ៉ាងដូច្នេះ ? យើងខ្ញុំយល់ឃើញថាត្រូវតែចោទ្ទលទោសបារាំង ។ ខ្ញុំឯណាទៅទទួលស្គាល់បន្ទាត់ប្រេវិយេ ដែលជាបន្ទាត់របស់លោកអគ្គទេសាភិបាលបារាំងនៅឥណ្ឌូចិន ។ ខ្ញុំធ្លាប់តែស្រែកថា បន្ទាត់ប្រេវិយេនេះមិនស្របច្បាប់ និងមិនមានគតិយុត្តិធម៌ទាល់តែសោះ ពោលគឺធ្វើបាបខ្មែរ ។ បន្ទាត់នេះត្រូវគូសឲ្យត្រង់តែមកដល់កោះត្រល់ បន្ទាត់ទៅជាវៀចកោង ដោយយកកោះត្រល់បញ្ចូលទៅឲ្យបារាំង ហើយបារាំងក៏ប្រគល់កោះនេះទៅវៀតណាម ។

ចំពោះកម្ពុជាក្រោមក្តី បន្ទាត់ប្រេវិយេក្តី ខ្ញុំមិនដែលបាននិយាយថាខ្ញុំសុខចិត្តប្រគល់ទៅឲ្យបារាំងនោះទេ ។ ខ្ញុំបានសុំឲ្យសហគមន៏អន្តរជាតិ និងអង្គការសហប្រជាជាតិទទួលស្គាល់ព្រំដែនកម្ពុជាបច្ចុប្បន្ន។ នេះពុំមែនមានន័យថា ខ្ញុំសុខចិត្តឲ្យកម្ពុជាក្រោម-កោះត្រល់ទៅបារាំង-វៀតណាមនោះទេ ។ យើងត្រូវដឹងខ្លួនថា យើងទន់ខ្សោយ ដូច្នេះយើងត្រូវគិតគូរទប់ទល់និងមារសត្រូវ ជាពិសេសទប់ទល់និងប្រទេសថៃ ប្រទេសវៀតណាមដែលខ្លាំងជាងយើង កុំឲ្យមកលេបត្របាក់ពង្រួញទំហំដីខ្មែរយើងតទៅទៀតបាន ។ ហេតុដូច្នេះហើយបានជាខ្ញុំសុំឲ្យប្រទេសនានាទទួលស្គាល់ជាផ្លូវការនូវព្រំដែនកម្ពុជានាបច្ចុប្បន្នកាល ។ ខ្ញុំសូមបញ្ជាក់ថា នេះមិនមែនមានន័យថាសុខចិត្តផ្ទេរកម្ពុជាក្រោម-កោះត្រល់ទៅឲ្យបារាំង និងវៀតណាមនោះទេ ។ ការពិតគឺសុំគេកុំឲ្យលេបត្របាក់ជាបន្តទៅទៀតនូវទិកដីកម្ពុជាដែលតូចណាស់ទៅហើយ គឺសុំឲ្យឈប់ត្រឹមហ្នឹងហើយ ! ត្បិតនៅពេលនោះ ង៉ោ ឌិន ដៀម (វៀតណាមខាងត្បូង)ទាមទារកោះសេះ កោះអន្តតាយ និងកោះដែលនៅជិតកែបពីកម្ពុជា ។

ដូច្នេះខ្ញុំសូមជនរួមជាតិមេត្តាបែងចែកឲ្យបានច្បាស់លាស់ពី:

ក-នរោត្តម សីហនុ មិនដែលទទួលស្គាល់ថាស្របច្បាប់ និងសមហេតុសមផលអំពីកម្ពុជាក្រោម-កោះត្រល់ បានទៅបារាំង-វៀតណាមនោះទេ ។

ខ-យើងមិនភ្លេចភ្លាំងថាយើងខ្សោយ កងទ័ពយើងមានចំនួនតិចជាងគេ ហើយយើងទ្រូវបញ្ឈប់ប្រទេសធំៗទាំងអស់ហ្នឹងកុំឲ្យវាទន្រ្ទានយកទឹកដីយើងសព្វថ្ងៃនេះតទៅទៀត ។ យើងខ្លាចទឹកដីយើងកាន់តែរួញតូចទៅៗ ។

នៅសតវត្សរ៍ទី២១នេះ ទឹកដីយើងបានបាត់បង់រួចទៅហើយ ។ ប្រជារាស្ត្រដែលធ្លាប់តែធ្វើស្រែចំ

ការពីដូនតាមកនៅលើទឹកដីរបស់ខ្លួន បានត្រូវវៀណាមប្រកាសថាជាទឹកដីរបស់គេ ។ លោមេធាវី Michel BUISSON រាយការណ៏របស់ឥស្សជេន និស្សិតជាច្រើនសុទ្ធតែបានបង្ហាញនូវការបាត់បង់ទឹកដី ។ ចំណែករដ្ឋអំណាចនៅតាមព្រំដែនវិញ គ្មាពុំហ៊ានធ្វើអត្ថាធិប្បាយអ្វីទេ ។

ដូច្នេះនាបច្ចុប្បន្នកាលនេះយើងបែកបាក់គ្នាទៅហើយរវាងអ្នកដែលនិយាយថាកម្ពុជាចំណេញទឹកដី (រហូតចំណេញទឹកជូនប្រជាពស្ត្រប្រើប្រាស់ទៀត) និងអ្នកដែលយល់ឃើញថាទឹដីកម្ពុជាបានត្រូវគេលេបត្របាក់ជាច្រើនណាស់ទៅហើយ ។ ការពិតវាយ៉ាងណាទៅ ? បច្ចុប្បន្ននេះខ្ញុំមិនធ្វើជាចៅក្រមកាត់សេចក្ដីថាខាងណាខុស ខាងណាត្រូវនោះទេ ។ ដោយហេតុនេះហើយបានជាខ្ញុំមិនវិលត្រឡប់ទៅកាន់មាតុប្រទេសវិញ ខ្ញុំសុំទោសផងចុះ ពីព្រោះការពិតយើងមិនទាន់ដឹងច្បាស់លាស់នៅឡើយទេ ។ ខ្ញុំសូមដកខ្លួនសិន ហើយសុំកុំឲ្យចោទខ្ញុំថាក្បត់ជាតិ ។ ខ្ញុំមិនដែលក្បត់ជាតិម្ដងណាទាល់តែសោះក្នុងមួយជីវភាពខ្ញុំនេះ ។ ផ្ទុយទៅវិញ ខ្ញុំមានតែការពារជាតិមិនដែលឈប់ឈរ ។ កូនចៅ ចៅទួតដែលសព្វថ្ងៃសេ់នៅសហរដ្ឋអាមេរិក ប្រទេសបារាំង អូស្ត្រាលី។ល។ ហើយដែលមានសេរីភាព បានផ្ញើអ៊ីមែលមកខ្ញុំកោតសរសើរសម្ដេចឪ សម្ដេចតាទួតថាខែងវែងមែន មិនដែលលះបង់ឧត្តមប្រយោជន៏ជាតិ បូរណភាពទឹកដីទេ ។ សម្ដេចតា សម្ដេចតាទួតជាអ្នកស្នេហាជាតិដ៏បរិសុទ្ធ ធំណាស់នៅក្នុងប្រវត្តិសាស្ត្រ ។

ខ្ញុំសូមបញ្ចប់តែត្រឹមនេះចុះ បើមានកិច្ចការអ្វីដែលអយុត្តិធម៏ចំពោះខ្ញុំទៀត ខ្ញុំនិងមិននៅស្ងៀមទេ គឺខ្ញុំតស៊ូជាដរាបរហូតដល់អវសាន្តនៃជីវិត ។ ប៉ុន្តែខ្ញុំសូមជន្ឋមជាតិមេត្តាយោគយល់ និងអភ័យទោស ដោយខ្ញុំមិនអាចចូលទៅក្នុងប្រទេសវិញ ត្បិតអយុត្តិធម៏មានច្រើនណាស់ចំពោះខ្ញុំ ។ ខ្ញុំនិងធ្វើតាមព្រះនរោត្តម យុគន្ធរ ដែលការពារឯករាជ្យ ការពារបូរណភាពទឹកដី ហ៊ានប្រឆាំងជាមួយបារាំងសែស ហើយដែលត្រូវបារាំងសែសនិរទេសព្រះអង្គទៅនៅបរទេស រហូតដល់ព្រះអង្គសុគត់ ។

ហត្ថលេខា : នរោត្តម សីហនុ

**កត់សម្គាល់ :**

លិខិតខាងលើនេះជាការបកប្រែដោះសារយកឬចខ្លួនរបស់អាក្បត់ជាតិឈ្មោះអា នរោត្តម សីហនុ ពីព្រោះបារាំងសែសបានប្រគល់ដែនដីកម្ពុជាក្រោមឲ្យទៅយួនកាលពីថ្ងៃទី០៤ ខែមិថុនា ឆ្នាំ១៩៤៩ នៅក្នុងរាជ្យរបស់អាក្បត់ជាតិឈ្មោះអានរោត្តម សីហនុនេះ ។ អាក្បត់ជាតិឈ្មោះអានរោត្តម សីហនុនេះ វាបានឡើងសោយរាជ្យសម្បត្តិលើបល្ល័ងនៅក្នុងព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៤១ ទៅដល់ឆ្នាំ១៩៥៥ ហើយវារំលោភ

ឡើងធ្វើជាប្រមុខរដ្ឋខុសនឹងច្បាប់របស់ព្រះរាជាណាចក្រកម្ពុជាពីឆ្នាំ១៩៦០ទៅដល់ថ្ងៃទី១៨ខែមិនាឆ្នាំ១៩៧០។ តាំងពីឆ្នាំ១៩៦០ដល់ឆ្នាំ១៩៧០ អាក្បត់ជាតិនរោត្តម សីហនុនេះ វាបានជួយលាក់បំពួនទ័ពយួនខាងជើងនឹងទ័ពយួនយៀកកុងឲ្យអាចប្រើប្រាស់ទឹកដីប្រទេសកម្ពុជាតាមបណ្តោលព្រំដែនជាមួយយួនតាំងពីខេត្តរតនៈគីរី,មណ្ឌលគីរី,ក្រចេះ,កំពង់ចាម,ព្រៃវែង,ស្វាយរៀង,កណ្តាល,តាកែវ រហូតដល់ខេត្តកំពត ដើម្បីច្បាំងដណ្តើមយកដែនដីកម្ពុជាក្រោម(យួនខាងត្បូង) ដែលវាបានប្រើឲ្យលោកលន់ ណុលឲ្យទៅចុះហត្ថលេខាជាមួយចិនអនុញ្ញាត្តិឲ្យយួនអាចប្រើប្រើប្រាស់ដែនដីកម្ពុជាធ្វើជាទីជម្រកទ័ពរបស់យួនកាលពីថ្ងៃទី២៥ខែវិច្ឆិកាឆ្នាំ១៩៦៥។ អាក្បត់ជាតិឈ្មោះអាននរោត្តមសីហនុនេះវាបានរត់ទៅចូលដៃជាមួយខ្មែរក្រហមតាំងពីឆ្នាំ១៩៧០រហូតដល់ឆ្នាំ១៩៧៩ ហើយបានឡើងធ្វើជាប្រធានាធិបតីខ្មែរក្រហម(កម្ពុជាប្រជាធិប្បតេយ្យ)ពីឆ្នាំ១៩៧៥ ដល់ ឆ្នាំ១៩៧៦ ដោយខ្មែរក្រហមបានដាក់ឈ្មោះងិន ឈនជាកម្មាភិបាលខ្មែរក្រហមឲ្យតាមយាមឃ្លាំមើលសកម្មភាពរបស់អាមេក្បត់ជាតិនរោត្តម សីហនុ កាលវាឡើងធ្វើជាប្រមុខរដ្ឋនៅក្នុងវាំងភ្នំពេញពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៦ ។ ឥឡូវនេះក្រោយពីនរោត្តម សីហនុបានងាប់ទៅកាលពីឆ្នាំ២០១២មក ឈ្មោះងិន ឈន បានតែងតាំងខ្លួនឯងជាតារូមរិត ។ កាលពីនរោត្តម សីហនុនៅរស់នៅឡើយមុនឆ្នាំ២០១២ ម្តេចឡើយងិន ឈន មិនប្រកាសថាខ្លួនឯង ជាតារូមរិតឲ្យគេឯងដឹងផង ? តារូមរិត ឬ តារូមរត់ ??? ។
ពីឆ្នាំ១៩៩០ដល់ឆ្នាំ១៩៩២ ពួកអាក្បាលយួនខ្លួនខ្មែរ មានជាអាទិ៍: អាជា ស៊ីម,អាហេង សំរិន នឹង អាហ៊ុន សែន បានតែងតាំងអាក្បត់ជាតិនរោត្តម សីហនុ ឲ្យឡើងធ្វើជាប្រមុខរដ្ឋនៃរដ្ឋកម្ពុជាចំនួន៣ឆ្នាំ ។ ពីឆ្នាំ១៩៩៣ ដល់ឆ្នាំ២០០៤ អាក្បត់ជាតិឈ្មោះនរោត្តម សីហនុ ត្រូវបានតែងតាំងឲ្យឡើងសោយរាជ្យម្តងទៀតជាលើកទី២នៅលើប្រទេសកម្ពុជា ឬ ព្រះរាជាណាចក្រអច្ឆរិយៈចោរ មានរយៈពេលចំនួន១២ឆ្នាំ ។ សូមកូនខ្មែរទាំងអស់គ្នាជួយពិចារណា តាំងពីឆ្នាំ១៩៤១ ដល់ ឆ្នាំ២០០៤ បានធ្វើជាស្តេចម៏ចំនួនពីរ(២)ផង បានធ្វើជាប្រមុខរដ្ឋចំនួនបី(៣)ផង ម្តេចឡើយអាក្បត់ជាតិនរោត្តម សីហនុនេះមិនទាមទារឲ្យបានស្វិតស្វាញឲ្យបានខ្លាំងក្លាដែនដីកម្ពុជាក្រោម នឹង កោះត្រល់ពីបារាំងសែស នឹងយួនមកវិញឲ្យទាល់តែបានមកបញ្ចូលក្នុងប្រទេសកម្ពុជារបស់ខ្លួនដែលខ្លួនថាមិនដែលសុខចិត្តសុខកាយប្រគល់កម្ពុជាក្រោម នឹង កោះត្រល់ឲ្យទៅបារាំង នឹង យួនម្តងណាសោះឡើយនេះ ??? ។ តាំងតែពីបារាំងប្រគល់កម្ពុជាក្រោមឲ្យទៅយួនពីថ្ងៃទី០៤ខែមិថុនាឆ្នាំ១៩៤៩ រហូតមកដល់ថៃទី១៦ ខែតុលា ឆ្នាំ២០០៥ ថ្ងៃដែលអាក្បត់ជាតិនរោត្តម សីហនុសរសេរលិខិតការពារខ្លួនវានេះ អាននរោត្តម សីហនុ មិនដែលហ៊ានហាមាត់ទាមទារកម្ពុជាក្រោមពីបារាំង

ម្តងណាទាល់តែសោះ ??? ។

ជាពិសេសនៅពេលក្រោយប្រទេសកម្ពុជាបានឯករាជ្យពេញបរិបូណ៌នៅថ្ងៃទី០៩ ខែវិច្ឆិកា ឆ្នាំ១៩៥៣ ហើយបានចូលជាសមាជិកនៃអង្គការសហប្រជាជាតិថែមទៀត ម្តេចឡើយអាក្បត់ជាតិនរោត្តម សីហនុ មិនយករឿងបារាំងប្រគល់កម្ពុជាក្រោមទៅឲ្យយួន ទៅប្តឹងតុលាការយុត្តិធម៌អន្តរជាតិ ឲ្យតុលាការនេះរកខុសត្រូវ ឲ្យកាត់សេចក្តីប្រគល់កម្ពុជាក្រោម មកកម្ពុជាវិញដូចដែលនរោត្តម សីហនុ បានប្តឹងឲ្យសៀមឲ្យប្រគល់ប្រាសាទព្រះវិហារមកខ្មែរវិញដោយជោគជ័យដូចកាលពីខែមិថុនា ឆ្នាំ១៩៦២ ផងទៅ ??? ។

ទង្វើអសកម្មរបស់នរោត្តម សីហនុក្នុងការមិនទាមទារកម្ពុជាក្រោម នឹង កោះត្រល់ពីបារាំងតាំងពីឆ្នាំ១៩៤១ រហូតមកដល់ឆ្នាំ២០០៥កន្លងទៅមុននេះដូចកូនខ្មែរបានឃើញផ្ទាល់នឹងភ្នែកនឹងបានឮផ្ទាល់នឹងត្រចៀកស្រាប់ មិនតែប៉ុណ្ណោះអាក្បត់ជាតិនរោត្តម សីហនុ នេះបានទទួលស្គាល់ថ្ងៃ៧មករា១៩៧៩ របស់អាមេចោរក្បត់ជាតិអាជា ស៊ីម,អាហេង សំរីន នឹង អាហ៊ុន សែន ហើយនឹងគាំទ្រទង្វើអាក្បត់ជាតិទាំងបីក្បាលនេះជាដរាបរៀងទៅលុះដល់ថ្ងៃវាងាប់តែហោង ។ មកដល់ខែវិច្ឆិការ ឆ្នាំ២០០៥ អាក្បត់ជាតិនរោត្តម សីហនុ បានបបួលកូនឈ្មោះអានរោត្តម សីហមុនី ជាស្តេចម៏ល្ងោនសោយរាជ្យនៅលើព្រះរាជាណាចក្រអច្ឆរិចោរសព្វថ្ងៃនេះឲ្យសុខចិត្តចុះហត្ថលេខាលើព្រះរាជក្រមដើម្បីទទួលស្គាល់សន្ធិសញ្ញាបំពេញបន្ថែមប្រគល់ទឹកដីតាមបណ្តោយព្រំដែនខ្មែរ-យួន ឲ្យទៅយួន ធ្វើឲ្យមានការមិនចុះសំរុងគ្នា តតាំងគ្នាយ៉ាងក្តៅគគុករវាងខ្មែរ នឹងខ្មែរ ។ ដូច្នេះសូមខ្មែរទាំងនៅក្នុងប្រទេសកម្ពុជា ទាំងនៅក្រៅប្រទេសកម្ពុជាត្រូវចាត់ទុកអាទាំងពីរក្បាលគឺ **អានរោត្តម សីហនុ នឹង អានរោត្តម សីហមុនី** ជាជនក្បត់ជាតិទាំងពីរក្បាលនៅលើប្រទេសកម្ពុជា ។

ភ្នំពេញ ថ្ងៃទី២៦ ខែសីហា ឆ្នាំ២០១៥

ខែម ខៀវ